អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

- ការធ្លាក់ចុះខ្លាំង ចរន្តនៃការដឹកជញ្ជូនទំនិញពីកម្ពុជាទៅប្រទេសថៃ មួយរយៈពេលចុងក្រោយនេះ
- កិច្ចប្រជុំរវាងគណៈកម្មការជំនាញនៃរដ្ឋសភា និងក្រសួងពាណិជ្ជកម្ម លើសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP)
- ប្រទេសសិង្ហបុរី ប្តេជ្ញាជួយស្តារវិស័យទេសចរណ៍កម្ពុជាឡើងវិញ
- យីហោមាន់ស្រែខ្មែរ កំពុងទាក់ទាញការលើកស្ទួយចូលក្នុងទីផ្សារ
- ស្ថិតិនាំចេញ និងនាំចូលរបស់ប្រទេសហ្វីលីពីន នៅខែមេសា ឆ្នាំ២០២១
- ការនាំចេញផលិតផលក្នុងស្រុកមិនមែនប្រេង (NODX) របស់សិង្ហបុរីសម្រាប់ខែមេសា ឆ្នាំ២០២១
- រដ្ឋាភិបាលថៃគ្រោងបង្កើនថវិកាវិនិយោគឆ្នាំ ២០២២ ចំនួន ៩០ ប៊ីលានបាត (២,៨៤ ប៊ីលានដុល្លារ)
- និយោជកសិង្ហបុរី នឹងទទួលទឹកប្រាក់ ២,២ ប៊ីលានដុល្លារសិង្ហបុរី ក្រោមគម្រោងគាំទ្រការងារ
- ប្រទេសឥណ្ឌូណេស៊ី ត្រូវបានជ្រើសរើសជាតំណាងអាស៊ីនៅក្នុងអង្គការស្បៀងអាហារ និងកសិកម្ម(FAO)
- ស្ថានភាពខុសគ្នា នៃសេដ្ឋកិច្ចនៅតំបន់ចាយប្រាក់អឺរ៉ូ និងសហរដ្ឋអាមេរិក
- បណ្តាប្រទេសនៅទ្វីបអាស៊ី ចាំបាច់គ្រប់គ្រងស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ-១៩ នាពេលបច្ចុប្បន្ន មុនពេលធនាគារកណ្តាលអាមេរិកដំឡើងអត្រាការប្រាក់
- រដ្ឋាភិបាលនៃសហព័ន្ធរុស្ស៊ី គ្រោងបង្កើនការវិនិយោគលើរថយន្តអគ្គិសនី(Electric Vehicle)


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី — អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គីម សុចិត្រា — អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី — ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមវរៈ — អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

# ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

## ចរន្តនៃការដឹកជញ្ជូនទំនិញ ពីប្រទេសកម្ពុជាទៅកាន់ប្រទេសថៃបានធ្លាក់ចុះខ្លាំងនារយៈពេលចុងក្រោយនេះ



*ប្រភព៖ cambonomist, 2021*
*រូបភាព៖ https://www.live-less-ordinary.com*

វិបត្តិកូវីដ-១៩ នៅដើមឆ្នាំនេះ កំពុងបន្តអូសបន្លាយ រួមទាំងការដាក់ចេញនូវវិធានការទប់ស្កាត់ការពារការឆ្លងជំងឺកូវីដ-១៩ បានធ្វើឲ្យចរន្តនៃការធ្វើពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងថៃ ធ្លាក់ចុះ និងជះឥទ្ធិពលមិនល្អមកលើការនាំចេញ-នាំចូល រវាងប្រទេសទាំងពីរ ជាពិសេសការនាំចេញរបស់ប្រទេសកម្ពុជាទៅកាន់ប្រទេសថៃ។

ទិន្នន័យក្រសួងពាណិជ្ជកម្មកម្ពុជាបានបង្ហាញថា៖ ការនាំចេញទំនិញរបស់ប្រទេសកម្ពុជាទៅកាន់ប្រទេសថៃនៅ៥ខែដំបូងនៃឆ្នាំ២០២១ សម្រេចបានតែជាង ១៥០លានដុល្លារប៉ុណ្ណោះ គឺធ្លាក់ចុះជាង២៩%បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។ ការធ្លាក់ចុះនេះកើតឡើងក្រោយមានការរឹតបន្តឹងតាមព្រំដែននៃប្រទេសទាំងពីរ ដោយសារវិធានការការពារនៃជំងឺកូវីដ-១៩។ ម្យ៉ាងទៀត ទំនិញចេញចូលនៃប្រទេសទាំងពីរត្រូវបានដោះដូរនៅតាមព្រំដែនរៀងៗខ្លួន។ ដោយឡែកសម្រាប់ការនាំចេញទំនិញពីប្រទេសថៃមកវិញ នៅតែរក្សាបានកំណើនជាង១% ដោយមានទំហំទឹកប្រាក់ប្រមាណជិត ១,៣ប៊ីលានដុល្លារ។

ស្របពេលជាមួយគ្នានេះដែរ ប្រទេសកម្ពុជា និងថៃ បានដាក់ផែនការរួមគ្នា ក្នុងការសម្រេចឲ្យបានទំហំពាណិជ្ជកម្មទ្វេភាគីដល់ទៅ១៥ប៊ីលានដុល្លារក្នុងមួយឆ្នាំ ប៉ុន្តែ រំលងប៉ុន្មានឆ្នាំហើយ ផែនការនេះហាក់នៅមិនទាន់សម្រេចបាននៅឡើយទេ។ ដូច្នេះអាចបញ្ជាក់ឲ្យឃើញថា គោលដៅទំហំពាណិជ្ជកម្ម ១៥ ប៊ីលានដុល្លារ កំពុងតែឃ្លាតឆ្ងាយពីផែនការរួមគ្នានៃប្រទេសទាំងពីរ។

យោងតាមទិន្នន័យកាលពីឆ្នាំ២០១៩ ទំហំពាណិជ្ជកម្មរវាងប្រទេសទាំង២ សម្រេចបានជាង ៩ប៊ីលានដុល្លារ ខណៈដែលកាលពីឆ្នាំ២០២០ ប្រទេសទាំងពីរសម្រេចបានទំហំពាណិជ្ជកម្មជាង ១០ប៊ីលានដុល្លារ។៚

*ដោយ សេន ចន្ទី*

*ប្រភព៖ cambonomist. ចេញផ្សាយថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១*

## គណៈកម្មការជំនាញនៃវុឌ្ឍសភា និងក្រសួងពាណិជ្ជកម្ម បានបើកកិច្ចប្រជុំពិនិត្យ សេចក្តីព្រាងច្បាប់ស្តីអំពីការអនុម័តកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP)




*ប្រភព៖ khmertime, 2021 រូបភាព៖ ក្រសួងពាណិជ្ជកម្ម*

កាលពីថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០២១ គណៈកម្មការជំនាញនៃវុឌ្ឍសភា បានបើកកិច្ចប្រជុំជាមួយក្រសួងពាណិជ្ជកម្ម ពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់(RCEP) ដើម្បីឱ្យសេចក្តីព្រាងច្បាប់នេះអាចចូលជាធរមានបាននៅដើមឆ្នាំក្រោយ។

ក្នុងកិច្ចប្រជុំនេះ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានលើកឡើងនៅក្នុងបទបង្ហាញថា សេចក្តីព្រាងច្បាប់ស្តីពី RCEP គឺមានភាពចាំបាច់សម្រាប់ការថែរក្សាទីផ្សារក្នុងចំណោមប្រទេសហត្ថលេខី នៃកិច្ចព្រមព្រៀងនេះ។ កិច្ចព្រមព្រៀង RCEP នឹងបង្កើតក្របខណ្ឌភាពជាដៃគូដែលមានលក្ខណៈទំនើប ទូលំទូលាយ គុណភាពខ្ពស់ ព្រមទាំងផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចឱ្យគ្នាទៅវិញទៅមក ដែលអាចជួយសម្រួលដល់ការពង្រីកខ្សែសង្វាក់ផ្គត់ផ្គង់ពាណិជ្ជកម្ម និងការវិនិយោគក្នុងតំបន់ ការផ្តល់សញ្ញាទៅកាន់ពិភពលោក អំពីការគាំទ្រលើប្រព័ន្ធពាណិជ្ជកម្មសេរីពហុភាគី ដែលផ្អែកលើគោលការណ៍ច្បាប់ និងជាពិសេសការរួមចំណែកក្នុងការស្តារសេដ្ឋកិច្ចកម្ពុជា និងតំបន់ឡើងវិញបានឆាប់រហ័ស ពីវិបត្តិជំងឺកូវីដ-១៩ ។

RCEP ត្រូវបានកំណត់ជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីធំជាងគេបំផុតរបស់ពិភពលោក ដែលដំបូងឡើយ មាន ១៦ប្រទេសជាសមាជិក ដែលមានប្រជាជនជាង ៣,៦ ប៊ីលាននាក់ ឬ៤៨,១%នៃចំនួនប្រជាជនពិភពលោក។ កិច្ចព្រមព្រៀងនេះ គឺជាគំនិតផ្តួចផ្តើមរបស់ ថ្នាក់ដឹកនាំអាស៊ាន និងត្រូវបានប្រកាសជាផ្លូវការក្នុងកិច្ចប្រជុំកំពូលលើកទី១២នៅរាជធានីភ្នំពេញដែលប្រទេសកម្ពុជាជាប្រធាន។ កិច្ចព្រមព្រៀងនេះ ត្រូវបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីនៃប្រទេសសមាជិក RCEP នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២០ក្នុងឱកាសនៃកិច្ចប្រជុំកំពូល RCEP លើកទី៤ ដែលបានធ្វើឡើងនៅទីក្រុងហាណូយ ប្រទេសវៀតណាមតាមប្រព័ន្ធអនឡាញ។

ផលិតផលក្នុងស្រុកសរុប(GDP) នៃប្រទេសសមាជិក RCEP មានចំនួន ២៨,៥ទ្រីលានដុល្លារក្នុងឆ្នាំ ២០១៩ ដែលស្មើនឹង ៣២,៧%នៃផលិតផលក្នុងស្រុកសរុបរបស់ពិភពលោក។ ពាណិជ្ជកម្មរួមគ្នានៃប្រទេសហត្ថលេខី មានលើសពី ១១,២ទ្រីលានដុល្លារ ស្មើនឹង ២៩,៥% នៃតម្លៃពាណិជ្ជកម្មពិភពលោក៕ *ដោយ សេន ចន្ទី*

*ប្រភព៖ khmertime. ចេញផ្សាយថ្ងៃទី២២ខែមិថុនា ឆ្នាំ២០២១*

## ប្រទេសសិង្ហបុរី ប្តេជ្ញាជួយស្តារវិស័យទេសចរណ៍កម្ពុជាឡើងវិញ




*ប្រភព៖ ThmeyThmey*

លោកជំទាវ យូ ឡេឆេង (Teo Lay Cheng) ជាឯកអគ្គរដ្ឋទូតសិង្ហបុរីថ្មីប្រចាំនៅកម្ពុជា បានលើកឡើងថា រដ្ឋាភិបាលសាធារណរដ្ឋសិង្ហបុរី បន្តគាំទ្រកិច្ចសហការជាមួយកម្ពុជា ដើម្បីស្តារឡើងវិញនូវវិស័យទេសចរណ៍ ដែលរងគ្រោះធ្ងន់ធ្ងរ ដោយសារជំងឺរាតត្បាតជាសកល កូវីដ-១៩។

ឯកឧត្តម ថោង ខុន ក៏បានលើកឡើងអំពីវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍រវាងកម្ពុជា និងសិង្ហបុរី ដែលធ្វើឱ្យមានកំណើនទេសចរទៅមករវាងប្រទេសទាំងពីរ នៅមុនពេលផ្ទុះជំងឺកូវីដ-១៩ ហើយជំងឺនេះបានរាតត្បាតពេញសកលលោក ក៏បានធ្វើឱ្យកំណើនទេសចរអន្តរជាតិនៅកម្ពុជាបានធ្លាក់ចុះយ៉ាងកំហុគ។ ដើម្បីឆ្លើយតបនឹងវិបត្តិវិស័យទេសចរណ៍ រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តដាក់ចេញ «ផែនទីចង្អុលផ្លូវស្តីពី ផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុងនិងក្រោយវិបត្តិកូវីដ-១៩។ ការដាក់ចេញផែនទីចង្អុលផ្លូវនេះ គឺដើម្បីធ្វើជាត្រីវិស័យក្នុងការស្តារ និងលើកស្ទួយវិស័យទេសចរណ៍ជាតិកម្ពុជាឡើងវិញ ហើយកម្ពុជាក៏ត្រូវការកិច្ចសហប្រតិបត្តិការពីបណ្តាប្រទេសជាដៃគូ ដោយក្នុងនោះក៏មានភាគីសិង្ហបុរី ផងដែរ»។

លោកជំទាវឯកអគ្គរដ្ឋទូត ក៏បានបង្ហាញការគាំទ្រ និងពេញចិត្តចំពោះកិច្ចសហប្រតិបត្តិជាមួយកម្ពុជា ក្នុងការស្តារវិស័យទេសចរណ៍នៅកម្ពុជាឡើងវិញ។ ហើយបានមានប្រសាសន៍ថា រដ្ឋាភិបាលសាធារណរដ្ឋសិង្ហបុរី នៅតែគាំទ្រកិច្ចសហការនេះ ក្នុងការអនុវត្តផែនការស្តារវិស័យទេសចរណ៍កម្ពុជាឡើងវិញ។

បើតាមការលើកឡើងរបស់លោកជំទាវ ពេលដែលវិបត្តិជំងឺកូវីដ-១៩បានធូរស្រាល ប្រទេសសិង្ហបុរី នឹងបង្កើនកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា ពិសេសលើការបណ្តុះបណ្តាលធនធានមនុស្ស និងការបើកឱ្យមានចលនាទេសចរទៅមកនៃប្រទេសទាំងពីរ ដោយគោរពតាមវិធានសុវត្ថិភាពរបស់ក្រសួងសុខាភិបាលរៀងៗខ្លួន។ លោកជំទាវ ក៏បានស្នើសុំកិច្ចសហការ ដើម្បីរៀបចំព្រឹត្តិការណ៍ ឬការតាំងពិព័រណ៍ទេសចរណ៍ នៅពេលសមស្របណាមួយ ដែលស្របនឹងវិធានសុវត្ថិភាពរបស់ក្រសួងសុខាភិបាល លើកស្ទួយវិស័យទេសចរណ៍នៃប្រទេសមិត្តទាំងពីរឡើងវិញ។

យោងតាមរបាយការណ៍ពីក្រសួងទេសចរណ៍ បានបង្ហាញថា ក្នុងត្រីមាសទីមួយនៃឆ្នាំ២០២១ កម្ពុជាទទួលភ្ញៀវទេសចរអន្តរជាតិ បានត្រឹម ៧០ ៩០១នាក់

ប៉ុណ្ណោះ។ ចំនួននេះគឺធ្លាក់ចុះរហូតដល់ ៩៣,៩% បើធៀបនឹងរយៈពេលដូចគ្នាកាលឆ្នាំ២០២០ ដែលកម្ពុជាទទួលបានភ្ញៀវទេសចរណ៍ជាង១,១៥លាននាក់។ កាលពីឆ្នាំ២០១៩ កម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិជាង៦,៦លាននាក់។ តែនៅក្នុង២០២០ កម្ពុជា ទទួលភ្ញៀងអន្តរជាតិ បានត្រឹមជាង១,៣លាននាក់ ប៉ុណ្ណោះ។ *ដោយ ម៉ែន ខេមរៈ*

*ប្រភព ៖ thmeythmey ចុះផ្សាយថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២១*

## ឃីហោមាន់ស្រែខ្មែរ កំពុងទាក់ទាញការលើកស្ទួយចូលក្នុងទីផ្សារ



ប្រភព៖ ភ្នំពេញប៉ុស្តិ៍   រូបថត៖ ក្រសួងកសិកម្ម

អង្គការហេហ្វឺអន្តរជាតិកម្ពុជា (HEIFER International Cambodia) បានអនុវត្តគម្រោងដែលមានទឹកប្រាក់សរុបជិត៥០ ម៉ឺនដុល្លារ ដើម្បីអភិវឌ្ឍឃីហោមាន់ស្រែចូលទៅក្នុងទីផ្សារ ក្រោមកម្មវិធី "សហគ្រាសកែច្នៃផលិតផលមាន់ស្រែខ្មែរ"។ កម្មវិធីនេះមានរយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០២១ ដល់២០២៦ ដើម្បីជួយផលិតកម្មមាន់ស្រែខ្មែរឱ្យមានការរីកលូតលាស់ តាមរយៈការពង្រឹងសមត្ថភាពសហគមន៍ និងអភិវឌ្ឍស្ថាប័នសហគមន៍កសិកម្ម។

គម្រោងនេះ ក៏ជំរុញការវិនិយោគលើការកសាងសហគ្រាសកែច្នៃផលិតផលមាន់ស្រែខ្មែរ ការកសាងកសិដ្ឋានភ្ញាស់កូនមាន់ស្រែស្តង់ដា និងការគាំទ្រវិនិយោគដល់គ្រួសារកសិករ ឱ្យឈានទៅរកការបង្កើតសហគ្រាសកសិកម្មខ្នាតតូច និងមធ្យម។

សហគមន៍កសិកម្ម គម្រោងកម្មវិធីស្តីពីសហគ្រាសកែច្នៃផលិតផលមាន់ស្រែខ្មែរនេះ នឹងទទួលបានរថយន្តចំនួន៧គ្រឿង និងរ៉ឺម៉កកង់បីចំនួន១៤គ្រឿង ពីអង្គការហេហ្វឺអន្តរជាតិកម្ពុជា ដើម្បីជាតម្រូវការបន្ទាន់សម្រាប់ប្រកបអាជីវកម្ម ក្នុងអំឡុងពេលវិបត្តិនៃជំងឺកូវីដ១៩។ ក្រៅពីនេះ អង្គការ នឹងប្រគល់ផ្សារសហគមន៍ ចំនួន៥កន្លែង ការិយាល័យសហគមន៍កសិកម្ម ៣កន្លែង និងឃ្លាំងត្រជាក់ ២កន្លែង ដើម្បីរួមចំណែកអនុវត្តគម្រោងនេះ។

កម្មវិធីនេះ នឹងផ្តល់ប្រយោជន៍ដោយផ្ទាល់ដល់គ្រួសារកសិករប្រមាណជាជាង ៥៣ ៣០០គ្រួសារក្នុងខេត្តចំនួន១១ ដើម្បីឈានទៅបង្កើនការផ្គត់ផ្គង់ស៊ុតមាន់ស្រែខ្មែរ កូនមាន់ស្រែខ្មែរ ការចិញ្ចឹមមាន់ស្រែខ្មែរយកសាច់ និងការកែច្នៃ និងវេចខ្ចប់សាច់មាន់ស្រែខ្មែរនៅក្នុងស្រុក។

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអះអាងថាគម្រោងនេះនឹងទទួលបានជោគជ័យខ្ពស់

ដោយសារ ផលិតផលមាន់ស្រែមានតម្រូវការខ្ពស់លើទីផ្សារ ហើយកសិករចិញ្ចឹមមាន់មានជំនាញ និងបច្ចេកទេសខ្លះរួចមកហើយ។

ជំនួយនេះ ជាសក្ខីកម្មបង្ហាញឱ្យឃើញយ៉ាងច្បាស់ពីការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃអភិក្រម «រដ្ឋដៃគូអភិវឌ្ឍន៍វិស័យឯកជន និងសហគមន៍កសិកម្ម» ដែលស្របនឹងគោលនយោបាយ និងផែនការអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០១៩-២០២៥។

ឯកឧត្តមរដ្ឋមន្ត្រីក៏សង្ឃឹមថា អង្គការហេហ្វឺអន្តរជាតិកម្ពុជា នឹងបន្តពិនិត្យលទ្ធភាពជួយដល់សហគមន៍កសិកម្មឱ្យបានកាន់តែច្រើនថែមទៀត ដើម្បីឆ្លើយតបតម្រូវការជាក់ស្តែង៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី២២ខែមិថុនា ឆ្នាំ២០២១*

## តារាងប្រចាំសប្តាហ៍៖

## តារាងទី១៖ ការប្រៀបធៀបការប្រមូលចំណូលរដ្ឋ ក្នុងខែមេសា ឆ្នាំ២០២១

| ចំណូល(ប៊ីលានរៀល) | អនុវត្តន៍ | | ច្បាប់ | | ធៀបនឹងច្បាប់ | | កំណើន(%) |
|---|---|---|---|---|---|---|---|
| | Apr-20 | Apr-21 | 2020 | 2021 | Apr-20 | Apr-21 | Apr-(2020-21) |
| ចំណូលក្នុងស្រុកសរុបថ្នាក់ជាតិ | **2,656** | **2,354** | **24,093** | **19,927** | **11.02%** | **11.81%** | **-11.38%** |
| ១.ចំណូលចរន្ត | **2,612** | **2,346** | **23,899** | **19,706** | **10.93%** | **11.91%** | **-10.20%** |
| ក.ចំណូលសារពើពន្ធ | 2,524 | 2,315 | 21,091 | 17,520 | 11.97% | 13.21% | **-8.28%** |
| ខ.ចំណូលមិនមែនសារពើពន្ធ | 89 | 32 | 2,808 | 2,186 | 3.16% | 1.44% | **-64.52%** |
| ២.ចំណូលមូលធន | **44** | **8** | **193** | **221** | **22.59%** | **3.56%** | **-81.98%** |

*ប្រភព៖ ការអនុវត្តថវិការដ្ឋ ខែធ្នូ ឆ្នាំ២០២០ និងការអនុវត្តថវិការដ្ឋ ខែមេសា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះនៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២១*

**តារាងទី១៖** យោងតាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបង្ហាញថា៖ ការអនុវត្តលើការប្រមូលចំណូលក្នុងស្រុកសរុបក្នុងខែមេសា ឆ្នាំ២០២១ មានការធ្លាក់ចុះ ១១% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។

ជាក់ស្តែង ក្នុងខែមេសា ចំណូលក្នុងប្រទេសសរុបថ្នាក់ជាតិអនុវត្តបានជិត ១២% នៃច្បាប់ហិរញ្ញវត្ថុ ឬ ស្មើនឹង ២ ៣៥៤ ប៊ីលានរៀល ។ ក្នុងនោះដែរ ចំណូលសារពើពន្ធមានចំនួនជិត ២ ៣១៥ ប៊ីលានរៀល ឬ ធ្លាក់ចុះ ៨% ដែលការធ្លាក់ចុះនេះ អាចបណ្តាលមកពីកត្តាមួយចំនួន ដូចជា ការធ្លាក់ចុះនូវប្រភពចំណូលពន្ធប្រយោល និងពាណិជ្ជកម្មក្រៅប្រទេស។ ចំណែកឯចំណូលមិនមែនសារពើពន្ធមានចំនួន ៣២ ប៊ីលានរៀល គឺធ្លាក់ចុះខ្លាំងជិត ៦៥% ដែលកំណើនថយនេះ បណ្តាលមកពីការធ្លាក់ចុះនៃការប្រមូលពន្ធ ផលទុននៃទ្រព្យសម្បត្តិរដ្ឋ ផលទុនពីសហគ្រាសសាធារណៈ ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវាកម្ម និងកម្រៃប្រតិបត្តិការផ្សេងៗ។ រីឯ ចំណូលមូលធនមានចំនួនប្រហែល ៨ ប៊ីលានរៀន ឬ ធ្លាក់ចុះយ៉ាងគំហុកជិត ៨២% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។

សរុបជារួម ការធ្លាក់ចុះនូវចំណូលថវិកាជាតិនេះ ត្រូវបានបង្ហាញថា ដោយសារការអូសបន្លាយនៃវិបត្តិជំងឺកូវីដ-១៩ ជាពិសេសព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ បាននឹងកំពុងបន្តដាក់សម្ពាធដល់ ការសម្រេចគោលដៅប្រមូលចំណូលប្រចាំឆ្នាំ២០២១ ៕ *ដោយ ឈន ហ៊ា*

### តារាងទី២៖ ការប្រៀបធៀបការចំណាយរបស់រដ្ឋ ក្នុងខែមេសា ឆ្នាំ២០២១

| ចំណាយ (ប៊ីលានរៀល) | អនុវត្តន៍ | | ច្បាប់ | | ធៀបនឹងច្បាប់ | | កំណើន (%) |
|---|---|---|---|---|---|---|---|
| | Apr-20 | Apr-21 | 2020 | 2021 | Apr-20 | Apr-21 | Apr-(2020-21) |
| **ចំណាយសរុបថ្នាក់ជាតិ** | **2,131** | **1,331** | **29,990** | **29,306** | **7.11%** | **4.54%** | **-37.56%** |
| **១.ចំណាយចរន្ត** | **1,500** | **1,117** | **18,037** | **17,447** | **8.32%** | **6.40%** | **-25.54%** |
| ក.ចំណាយបៀវត្ស | 576 | 614 | 8,540 | 7,981 | 6.74% | 7.69% | **6.61%** |
| ខ.ចំណាយមិនមែនបៀវត្ស | 925 | 503 | 9,497 | 9,466 | 9.74% | 5.32% | **-45.56%** |
| **២.ចំណាយមូលធន** | **631** | **213** | **11,953** | **11,859** | **5.28%** | **1.80%** | **-66.16%** |

*ប្រភព៖ ការអនុវត្តថវិការដ្ឋ ខែធ្នូ ឆ្នាំ២០២០ និងការអនុវត្តថវិការដ្ឋ ខែមេសា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះនៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២១*

**តារាងទី២៖** យោងតាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបង្ហាញថា៖ ការអនុវត្តលើការចំណាយសរុបថ្នាក់ជាតិ ក្នុងខែមេសា ឆ្នាំ២០២១ មានការធ្លាក់ចុះជិត ៣៨% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។

ជាក់ស្តែង ក្នុងខែមេសា ឆ្នាំ២០២១នេះ ការចំណាយក្នុងប្រទេសសរុបថ្នាក់ជាតិអនុវត្តបានជិត ៥% នៃច្បាប់ហិរញ្ញវត្ថុ ឬស្មើនឹង ១ ៣៣១ ប៊ីលានរៀល។ ក្នុងនោះដែរ ចំណាយលើបៀវត្ស មានចំនួន ៦១៤ ប៊ីលានរៀល ឬ កើនជិត ៧% គឺបណ្តាលមកការអនុវត្តចំណាយលើផ្នែកការពារជាតិ និងសន្តិសុខដែលកើនទៅដល់ ៤៥% ខណៈរដ្ឋបាលស៊ីវិលបានថយចុះ ១៣%។ ចំណែកឯចំណាយមិនមែនបៀវត្សមានចំនួន ៥០៣ ប៊ីលានរៀល គឺធ្លាក់ចុះយ៉ាងខ្លាំងជិត ៤៦% ដែលការធ្លាក់ចុះនេះបណ្តាលមកពីការកាត់បន្ថយការចំណាយ លើការទិញសេវាកម្ម អត្ថប្រយោជន៍សង្គម និងឧបត្ថម្ភធន។ រីឯចំណាយមូលធន ក៏ធ្លាក់ចុះយ៉ាងខ្លាំងផងដែរប្រមាណ ៦៦% មកនៅត្រឹមចំនួន ២១៣ ប៊ីលានរៀល ដែលការធ្លាក់ចុះនេះ ដោយសារការថយចុះវិនិយោគដោយហិរញ្ញប្បទានខាងក្នុង(គម្រោង) អចលនកម្មរូបី និង វិនិយោគដោយហិរញ្ញប្បទានខាងក្រៅ(គម្រោង) បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។

ជារួម ការអនុវត្តចំណាយឆ្នាំ២០២១ អាចស្ថិតក្នុងកម្រិតដែលអាចគ្រប់គ្រងបាន តាមរយៈការរឹតបន្តឹងចំណាយមិនចាំបាច់ ឬលែងចាំបាច់ និងការបង្វែរមុខសញ្ញាអនុវត្តឱ្យចំគោលដៅ ប្រកបដោយបុរេសកម្ម ដើម្បីបន្តដោះស្រាយផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩៕ *ដោយ ឈន ហាំ*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ស្ថិតិនាំចេញ និងនាំចូលរបស់ប្រទេសហ្វីលីពីន នៅខែមេសា ឆ្នាំ២០២១

យោងតាមតារាងខាងក្រោម ពាណិជ្ជកម្មទំនិញសរុបរបស់ប្រទេសហ្វីលីពីនក្នុងខែមេសាឆ្នាំ២០២១ មានចំនួន ១៤ ១៦៣លានដុល្លារ បានកើនឡើង ១០៧,៥%។ នៅក្នុងខែមីនា អត្រាកំណើនប្រចាំឆ្នាំដែលបានកត់ត្រាមាន ២៦,៥% ខណៈដែលកាលពីខែមេសា ឆ្នាំ២០២០ មានអត្រាធ្លាក់ចុះ (-៥៤,៨%)។ ក្នុងចំណោមពាណិជ្ជកម្មខាងក្រៅសរុបនៅក្នុងខែមេសា

ឆ្នាំ២០២១ ការនាំចូលមានចំណែក៥៩,៧% ខណៈដែលការនាំចេញមាន ប្រមាណ ៤០,៣%។

តុល្យភាពពាណិជ្ជកម្ម គឺជាភាពខុសគ្នារវាងតម្លៃនៃការនាំចេញ និងការនាំចូល។ នៅក្នុងខែមេសា ឆ្នាំ២០២១ ហ្វីលីពីនមានឱនភាពពាណិជ្ជកម្ម ចំនួន ២ ៧៣៤ លានដុល្លារអាមេរិក។ ឱនភាពពាណិជ្ជកម្មកាលពីខែមីនា ដែលបានកត់ត្រា មានកំណើនប្រចាំឆ្នាំ ចំនួន០,៩% ខណៈខែមេសា ឆ្នាំ២០២០ មានអត្រាកំណើនថយចុះដល់ ៩៥,១%។

សម្រាប់ការនាំចេញសរុប នៅក្នុងខែមេសា ឆ្នាំ២០២១ មានចំនួន ៥ ៧១៤ លានដុល្លារអាមេរិក កើនឡើងក្នុងអត្រាប្រចាំឆ្នាំ ៧២,១% ពីកំណើន ៣៣,៣% កាលពីខែមុន។ នៅក្នុងខែមេសា ឆ្នាំ២០២០ ការនាំចេញសរុបបានធ្លាក់ចុះក្នុងអត្រាប្រចាំឆ្នាំ (-៤១,៣%)។

ដោយឡែក ការនាំចូលសរុបក្នុងខែមេសា ឆ្នាំ២០២១ មានទឹកប្រាក់ចំនួន ៨ ៤៤៨ លានដុល្លារអាមេរិក ដោយបានកើនឡើងក្នុងអត្រាប្រចាំឆ្នាំ ១៤០,៩%។ នៅក្នុងខែមីនា ឆ្នាំ២០២១ កំណើនប្រចាំឆ្នាំមាន២២% ខណៈនៅក្នុងខែមេសា ឆ្នាំ២០២០ ការនាំចូលសរុបរបស់ប្រទេសនេះ មានកំណើនថយចុះ(-៦២,៩ %)។

*ដោយ ជឹម ប៊ុនធឿន*

| សូចនាករ | មេសា ២០២០ | | មីនា ២០២១ (កែតម្រូវ) | | មេសា២០២១ (បឋម) | |
|---|---|---|---|---|---|---|
| | តម្លៃគិតជាដុល្លារ (លានដុល្លារ) | កំណើនប្រចាំឆ្នាំ(%) | តម្លៃគិតជាដុល្លារ (លានដុល្លារ) | កំណើនប្រចាំឆ្នាំ(%) | តម្លៃគិតជាដុល្លារ (លានដុល្លារ) | កំណើនប្រចាំឆ្នាំ(%) |
| ពាណិជ្ជកម្មសរុប | 6 827.05 | -54.8 | 16 295.71 | 26.5 | 14 163.46 | 107.5 |
| តុល្យភាពពាណិជ្ជកម្ម | -187.1 | -95.1 | -2 751.64 | 0.9 | -2 734.32 | 1 361.5 |
| ការនាំចេញ | 3 319.97 | -41.3 | 6 772.04 | 33.3 | 5 714.57 | 72.1 |
| ការនាំចូល | 3 507.07 | -62.9 | 9 523.67 | 22.0 | 8 448.89 | 140.9 |

*ប្រភព៖ Philippine Statistics Authority*

## ការនាំចេញផលិតផលក្នុងស្រុកមិនមែនប្រេង (NODX) របស់សិង្ហបុរីសម្រាប់ខែមេសា ឆ្នាំ២០២១

យោងតាមតារាងខាងក្រោម ការនាំចេញផលិតផលក្នុងស្រុកមិនមែនប្រេង (NODX) របស់សិង្ហបុរីទៅក្នុងទីផ្សារធំៗទាំង១០ បានធ្លាក់ចុះនៅខែមេសា ឆ្នាំ២០២១។

NODX ទៅកាន់ទីផ្សារសហរដ្ឋអាមេរិកថយចុះ ៤២,៣% ធៀបទៅនឹងខែមីនា ដែលបានធ្លាក់ចុះជិត២០%។ ការធ្លាក់នោះ គឺដោយសារមាសមិនមែនរូបិយវត្ថុ(non-monetary gold) ថយចុះ៩៩,៨% ការត្រៀមបម្រុងអាហារ(Food preparations)ថយចុះ១២,១% និង

ផលិតផលប្រព័ន្ធឌីស(disk media products)ថយចុះ ៦៣,១%។

NODX ទៅកាន់ទីផ្សារសហភាពអឺរ៉ុប បានធ្លាក់ចុះ៣០,២% ក្នុងខែមេសា ឆ្នាំ២០២១ បន្ទាប់ពីការកើនឡើង៣១,៦% កាលពីខែមីនា ដោយសារតែការនាំចេញឱសថ ធ្លាក់ចុះ ៦៤,៥% ផលិតផលផ្សេងៗទៀត (miscellaneous manufactured articles) ធ្លាក់ចុះ ៣៨,៦% និងបរិក្ខារពេទ្យ ធ្លាក់ចុះ ២៣,០% ។

NODX ទៅកាន់ទីផ្សារជប៉ុនថយចុះ ៣៣,២% នៅក្នុងខែមេសា ឆ្នាំ២០២១ ខណៈកាលពីខែមីនា ថយចុះជាង ២៨% ដោយសារឱសថធ្លាក់ចុះ ៨២,៣% គ្រឿងម៉ាស៊ីនឯកទេសធ្លាក់ចុះ ៥៥,៦% និងបរិធានវេជ្ជសាស្ត្រ (medical apparatus) ធ្លាក់ចុះ ៦២,២% ។

NODX ទៅកាន់ទីផ្សារកំពុងងើបឡើង (Caribbean, Central Asia, CLMV (Cambodia, Laos, Myanmar and Vietnam), Eastern & Southern Europe (non-EU), Latin America, the Middle East, South Asia and South Africa) មានកំណើន ៧០,៥% នៅក្នុងខែមេសា ឆ្នាំ២០២១ ធៀបនឹងខែមីនា ឆ្នាំ២០២១។ កំណើននាំចេញទៅទីផ្សារអាស៊ីខាងត្បូងមាន ២០២,៣% CLMV (ខ្មែរ ឡាវ មីយ៉ាន់ម៉ា និងវៀតណាម) មាន៦៨,៥% និងមជ្ឈឹមបូព៌ា មាន ៤៩,១%។ សូមបញ្ជាក់ថា NODX របស់ប្រទេសសិង្ហបុរីទៅកាន់ទីផ្សារពិភពលោកនៅតែកើនឡើងក្នុងខែមេសា ឆ្នាំ២០២១៕ *ដោយ ជឹម ប៊ុនធឿន*

| ទីផ្សារទាំង១០ | NODX | |
|---|---|---|
| | មីនា 2021 | មេសា 2021 |
| អាមេរិក | -19.8 | -42.3 |
| អឺរ៉ុប | 31.6 | -30.2 |
| ជប៉ុន | -28.7 | -33.2 |
| ថៃ | -50.7 | 9.7 |
| តៃវ៉ាន់ | 24.0 | 14.9 |
| ឥណ្ឌូនេស៊ី | 25.4 | 28.3 |
| កូរ៉េខាងត្បូង | 17.3 | 25.0 |
| ហុងកុង | -13.1 | 30.9 |
| ម៉ាឡេស៊ី | 46.9 | 57.1 |
| ចិន | 46.4 | 55.5 |

*ប្រភព៖ hhttps://www.enterprisesg.gov.sg*

## រដ្ឋាភិបាលថៃ គ្រោងបង្កើនថវិកាវិនិយោគ ឆ្នាំ២០២២ ចំនួន ៩០ ប៊ីលានបាត (២,៨៤ ប៊ីលានដុល្លារ)



*ប្រភព៖ National News Bureau of Thailand*

យោងតាមការិយាល័យថវិកាថៃ រដ្ឋាភិបាលថៃគ្រោងនឹងបង្កើនថវិកាវិនិយោគរបស់ខ្លួន ចំនួន៩០ប៊ីលានបាត ក្នុងឆ្នាំសារពើពន្ធ២០២២ ស្របតាមច្បាប់ទាក់ទងនឹងហិរញ្ញវត្ថុ និងសារពើពន្ធរបស់រដ្ឋ។ ក្នុងនោះ រដ្ឋាភិបាលគ្រោងនឹងបន្ថែមថវិកាវិនិយោគឆ្នាំ២០២២ ចំនួន៥០ ទៅ៦០ប៊ីលានបាត គឺបានមកពីប្រាក់កម្ចីបន្ទាន់ចំនួន ៥០០ ប៊ីលានបាត និងថវិកាដែលនៅសល់ គឺបានមកពីថវិកាវិនិយោគឆ្នាំ២០២២របស់ទីភ្នាក់ងារ និងសហគ្រាសរដ្ឋ។

ជាមួយគ្នានេះ យោងតាមសេចក្តីព្រាងច្បាប់ថវិកាជាតិឆ្នាំ២០២២ បានកំណត់ចំណាយសាធារណៈ ចំនួន ៣,១ ទ្រីលានបាត ស្មើនឹង ១៧,៩%នៃផ.ស.ស. ដែលធ្វើឱ្យរដ្ឋាភិបាលមានតម្រូវការក្នុងការខ្ចីប្រាក់៧០០ប៊ីលានបាត ដើម្បីទូទាត់ឱនភាព។ ទោះបីជាយ៉ាងណា ច្បាប់នេះកំណត់ថវិកាវិនិយោគត្រឹមតែ ៦២៤ ប៊ីលានបាត ទាបជាងឱនភាពថវិកាដែលមានចំនួន ៧០០ប៊ីលានបាត។ នេះមានន័យថា រដ្ឋាភិបាល នឹងត្រូវបង្កើនថវិកាវិនិយោគច្រើនជាង៧០០ប៊ីលានបាត ដើម្បីអនុវត្តតាមច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ និងសារពើពន្ធរបស់រដ្ឋ ឆ្នាំ ២០១៨ ព្រោះថា ថវិកាវិនិយោគមិនត្រូវតិចជាងចំនួនឱនភាពក្នុងថវិកាប្រចាំឆ្នាំរបស់រដ្ឋឡើយ។

*ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ គេហទំព័រព័ត៌មាន ThailandBusinessNews.com ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១*

## និយោជក នឹងទទួលបានទឹកប្រាក់ ២,២ ប៊ីលានដុល្លារសិង្ហបុរី ចាប់ពីថ្ងៃទី៣០ មិថុនា ក្រោមគម្រោងគាំទ្រការងារ




*ប្រភព៖ CNA, រូបភាព៖ Jeremy Long*

និយោជក ជាង១៤ម៉ឺននាក់នៅក្នុងប្រទេសសិង្ហបុរី នឹងទទួលបានទឹកប្រាក់ចំនួន ២,២ ប៊ីលានដុល្លារសិង្ហបុរី ក្រោមគម្រោងគាំទ្រការងារ(Jobs Support Scheme) ចាប់ពីថ្ងៃទី៣០ ខែមិថុនា ដែលការចំណាយនេះ នឹងត្រូវបានផ្តល់សម្រាប់គាំទ្រដល់ប្រាក់ឈ្នួលរបស់និយោជិតក្នុងស្រុក ជាង២លាននាក់។

ជាមួយគ្នានេះ ចាប់តាំងពីពេលដាក់អោយប្រើប្រាស់នាខែកុម្ភៈឆ្នាំ២០២០ គម្រោង JSS នេះ បានចំណាយច្រើនជាង ២៦,៧ ប៊ីលានដុល្លារសិង្ហបុរី ដើម្បីឧបត្ថម្ភធនដល់ប្រាក់ឈ្នួលរបស់ប្រជាជនសិង្ហបុរី និងអ្នករស់នៅជាអចិន្ត្រៃយ៍ ដើម្បីជួយក្រុមហ៊ុនដែលរងផលប៉ះពាល់ដោយជំងឺកូវីដ-១៩។ និយោជក ដែលបានចូលរួមវិភាគទាន ក្នុងមូលនិធិសោធន៍និវត្តន៍ (Central Provident Fund) ដែលចាំបាច់សម្រាប់និយោជិតក្នុងស្រុករបស់ខ្លួនសម្រាប់ខែមករាដល់ខែមីនាឆ្នាំនេះ តាមកាលបរិច្ឆេទកំណត់ នឹងទទួលបានទឹកប្រាក់ក្រោមគម្រោង JSS នេះ។

ដោយឡែក សម្រាប់ការទូទាត់នាពេលខាងមុខ នៅខែមិថុនា និយោជកក្នុងវិស័យអាកាសចរណ៍ និងអវកាស និងវិស័យទេសចរណ៍ នឹងទទួលបានប្រាក់ឧបត្ថម្ភ៥០% សម្រាប់ប្រាក់ឈ្នួលសរុបប្រចាំខែដំបូងចំនួន ៤ ៦០០ ដុល្លារសិង្ហបុរី ដែលបានបង់ចាប់ពីខែមករាដល់ខែមីនា។ ខណៈពេលដែលនិយោជិក នៅក្នុងសេវាកម្មម្ហូបអាហារ ការលក់រាយ សិល្បៈ និងការកម្សាន្ត ការដឹកជញ្ជូន ដីធ្លីបរិស្ថាន និងឧស្សាហកម្មសមុទ្រ និងដើងទឹក នឹងទទួលបានប្រាក់ឧបត្ថម្ភ ៣០%។ វិស័យផ្សេងទៀត នឹងទទួលបានប្រាក់ឧបត្ថម្ភ ១០%។

ទន្ទឹមនឹងនេះ វិស័យដែលនឹងមិនទទួលបានឧបត្ថម្ភធនគឺវិទ្យាសាស្ត្រជីវសាស្ត្រ វិស្វកម្ម អេឡិចត្រូនិក សេវាកម្មហិរញ្ញវត្ថុ បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ប្រព័ន្ធផ្សព្វផ្សាយ ប្រៃសណីយ៍ ការលក់រាយតាមអ៊ីនធឺណិត និងផ្សារទំនើប និងហាងលក់ទំនិញគ្រឿងទេសផ្សេងៗ។

*ដោយ វត្តា វង្សវឌ្ឍនៈ*

*ប្រភព៖ គេហទំព័រសារព័ត៌មាន channelnewsasia.com ចុះថ្ងៃទី២២ ខែមីថុនា ឆ្នាំ២០២១*

## ប្រទេសឥណ្ឌូណេស៊ី ត្រូវបានជ្រើសរើសជាតំណាងអាស៊ីនៅក្នុងអង្គការស្បៀងអាហារ និងកសិកម្ម(FAO)




*ប្រភព៖ ក្រសួងព័ត៌មាន*

ប្រទេសឥណ្ឌូណេស៊ី ត្រូវបានបោះឆ្នោតជ្រើសរើសចូលក្នុងក្រុមប្រឹក្សានៃអង្គការស្បៀងអាហារ និងកសិកម្ម (FAO) នៅក្នុងសម័យប្រជុំលើកទី ៤២ នៃសន្និសីទអង្គការ FAO ដែលបានធ្វើឡើងកាលពីថ្ងៃទី ១៤ ដល់ថ្ងៃទី១៨ ខែមិថុនា។

ប្រទេសឥណ្ឌូណេស៊ី គឺជាអ្នកតំណាងនៃក្រុមប្រចាំតំបន់អាស៊ី រួមជាមួយប្រទេសនៅអាស៊ីចំនួន ៥ ផ្សេងទៀត គឺ បង់ក្លាដែស ចិន ជប៉ុន ហ្វីលីពីន និងកូរ៉េខាងត្បូង សម្រាប់ឆ្នាំ ២០២១-២០២៤។

ថ្លែងនៅក្នុងសន្និសីទសារព័ត៌មានមួយកាលពីថ្ងៃទី ២១ ខែមិថុនា រដ្ឋមន្ត្រីក្រសួងកសិកម្មឥណ្ឌូណេស៊ី លោក Syahrul Yasin Limpo បាននិយាយថា ការបោះឆ្នោតនេះ គឺជាទម្រង់នៃការទទួលស្គាល់ជាអន្តរជាតិ អំពីការរីកចម្រើននៃវិស័យកសិកម្មរបស់ឥណ្ឌូណេស៊ី។

លោកបានកត់សម្គាល់ថា កម្មវិធីអភិវឌ្ឍវិស័យកសិកម្មក្រោមការដឹកនាំរបស់លោកប្រធានាធិបតីឥណ្ឌូណេស៊ី

លោក ចូកូ វីដូដូ បានបង្កើតលទ្ធផលវិជ្ជមានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច។

លោកបានបន្តថា កម្មវិធីនេះត្រូវបានគេរំពឹងថា នឹងដាក់ចេញនូវពណ៌គោលនយោបាយកសិកម្មពិភពលោក និងជំរុញប្រទេសដទៃទៀត ហើយតណ្ឌូណេស៊ីអាចដើរតួនាទីក្នុងការផ្គត់ផ្គង់ស្បៀងអាហារ ដល់សហគមន៍ពិភពលោក។

តាមរយៈសមាជិកភាពនៅក្នុងក្រុមប្រឹក្សានោះ ប្រទេសនេះ អាចចូលរួមចំណែកក្នុងការបង្កើតគោលនយោបាយរបស់អង្គការFAO ដែលគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋជាសមាជិកអង្គការសហប្រជាជាតិ ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ក្នុងចំណោមប្រទេសដទៃទៀត៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ AKP ភ្នំពេញថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០២១*

## សេដ្ឋកិច្ចសកល

### សេដ្ឋកិច្ចនៅតំបន់ចាយប្រាក់អឺរ៉ូ និងសហរដ្ឋអាមេរិក កំពុងស្ថិតក្នុងស្ថានភាពខុសគ្នា បើយោងតាមប្រសាសន៍របស់ប្រធានធនាគារកណ្តាលសហភាពអឺរ៉ុប



*ប្រភព៖ Reuters២០២១, រូបភាព៖ Reuters /Kai Pfaffenbach*

តំបន់ចាយប្រាក់អឺរ៉ូ និងសហរដ្ឋអាមេរិក កំពុងស្ថិតក្នុងស្ថានភាពខុសគ្នាយ៉ាងច្បាស់ នៅពេលនិយាយអំពីទស្សនវិស័យអតិផរណា នេះបើយោងតាមប្រសាសន៍របស់លោកស្រី Christine Lagarde ប្រធានធនាគារកណ្តាលសហភាពអឺរ៉ុប ។ ទោះជាយ៉ាងនេះក្តី លោកស្រីបានច្រានចោល ការប្រៀបធៀបរវាងសេដ្ឋកិច្ចទាំងពីរដែលនិយាយថា ការងើបឡើងវិញនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក គឺនាំមុខឆ្ងាយជាងសេដ្ឋកិច្ចនៅតំបន់ចាយប្រាក់អឺរ៉ូ ដោយសារ ភាពខុសគ្នាច្រើនរវាងសេដ្ឋកិច្ចទាំងពីរនោះ។

លោកស្រី Lagarde បានទទួលស្គាល់ថាអាចនឹងមានការលេចចេញនូវការកើនឡើងនៃអតិផរណាមួយចំនួននៅសហរដ្ឋអាមេរិក តាមរយៈតម្លៃនាំចូលខ្ពស់ ការនាំចេញកាន់តែខ្លាំង និងការរំពឹងទុករបស់ពលរដ្ឋនៅតំបន់ចាយប្រាក់អឺរ៉ូអំពីអតិផរណា។ ប៉ុន្តែ ជារួមផលប៉ះពាល់នៃអតិផរណានៅតំបន់ចាយប្រាក់អឺរ៉ូ ត្រូវបានរំពឹងថាមានកម្រិតមធ្យម។

លោកស្រីបានបន្ថែមទៀតថា ធនាគារកណ្តាលសហភាពអឺរ៉ុប បានប៉ាន់ប្រមាណនូវផលប៉ះពាល់សរុបដែលអាចនឹងមានចំនួន ០,១៥ពិន្ទុភាគរយ លើអតិផរណា និង ០,៣ពិន្ទុភាគរយ លើកំណើនសេដ្ឋកិច្ច នៅចន្លោះឆ្នាំ២០២១ និង២០២៣ នៅក្នុងតំបន់ចាយប្រាក់អឺរ៉ូ ដោយសារតែកញ្ចប់ជំរុញសេដ្ឋកិច្ចអាមេរិក ហើយនេះគឺជាការបញ្ជាក់ជាថ្មីពីការព្យាករណ៍កាលពីខែមីនា ឆ្នាំ ២០២១ របស់ខ្លួន។

លោកស្រី Lagarde ក៏បានថ្លែងសាររបស់លោកស្រីម្តងទៀតដែរ បន្ទាប់ពីកិច្ចប្រជុំគោលនយោបាយចុងក្រោយរបស់ធនាគារកណ្តាលសហភាពអឺរ៉ុប កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ថាវាមិនទាន់ដល់ពេលអនុញ្ញាតឱ្យអត្រាការប្រាក់កើនឡើងទេ។ ដូច្នេះ ធនាគារកណ្តាលនឹងរក្សាលក្ខខណ្ឌហិរញ្ញប្បទានអំណោយផល។

ទោះជាយ៉ាងណា ការបន្តកើនឡើងនូវអត្រាទីផ្សារអាចបណ្តាលឱ្យមានការរឹតបន្តឹងកាន់តែខ្លាំងចំពោះលក្ខខណ្ឌហិរញ្ញប្បទាន ដែលនឹងប៉ះពាល់ដល់សេដ្ឋកិច្ចទាំងមូល។ ខណៈ ការរឹតបន្តឹងបែបនេះ អាចឆាប់ពេក និងអាចបង្ហានិភ័យដល់ការបន្តងើបឡើងវិញនៃសេដ្ឋកិច្ច និងទស្សនវិស័យអតិផរណា៕ *ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ គេហទំព័រសារព័ត៌មាន Reuters ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១*

## បណ្តាប្រទេសនៅទ្វីបអាស៊ី ចាំបាច់គ្រប់គ្រងឱ្យបាននូវស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ-១៩ នាពេលបច្ចុប្បន្ន មុនពេលធនាគារកណ្តាលអាមេរិកដំឡើងអត្រាការប្រាក់




*ប្រភព៖ CNBC ២០២១*

យោងតាមប្រសាសន៍របស់លោក Steve Cochrane ប្រធានសេដ្ឋវិទូប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក នៃក្រុមហ៊ុន Moody's Analytics បណ្តាប្រទេសនៅទ្វីបអាស៊ី ត្រូវទប់ស្កាត់ឱ្យបាននូវរលកនៃការផ្ទុះឡើងនៃជំងឺកូវីដ-១៩ នាពេលបច្ចុប្បន្ន ដើម្បីត្រៀមខ្លួនសម្រាប់ការដំឡើងអត្រាការប្រាក់នាពេលអនាគត របស់ធនាគារកណ្តាលសហរដ្ឋអាមេរិក។

ជាក់ស្តែង ធនាគារកណ្តាលសហរដ្ឋអាមេរិក បានបញ្ជាក់កាលពីសប្តាហ៍មុនថា ការដំឡើងអត្រាការប្រាក់អាចនឹងធ្វើឡើងនាពេលឆាប់ៗ នៅក្នុងឆ្នាំ២០២៣ ដោយផ្ទុយពីការអត្ថាធិប្បាយកាលពីដើមខែមីនា ឆ្នាំ២០២១ ដែលថា ខ្លួនមិនរំពឹងថានឹងមានការដំឡើងអត្រាការប្រាក់ទេ រហូតយ៉ាងហោចណាស់ឆ្នាំ២០២៤។

ស្របជាមួយគ្នានេះ លោក Cochrane បានព្យាករណ៍ថា ធនាគារកណ្តាលសហរដ្ឋអាមេរិក អាចនឹងដំឡើងអត្រាការប្រាក់ចំនួន ២៥ពិន្ទុគោលម្តង រៀងរាល់ត្រីមាស ចាប់ពីឆ្នាំ២០២៣ ទៅ។ អ្វីដែលគេហៅថាដាក់ចម្រិតពិន្ទុ (dot plot) នៃការរំពឹងទុករបស់សមាជិកម្នាក់ៗរបស់ធនាគារកណ្តាលសហរដ្ឋអាមេរិក បានបង្ហាញថានឹងមានការកើនឡើងពីរដងនៅឆ្នាំ២០២៣នោះ។

អត្រាការប្រាក់ខ្ពស់នៅសហរដ្ឋអាមេរិក អាចនឹងទាក់ទាញវិនិយោគិនពីបរទេស ខណៈធនាគារកណ្តាលនៅបណ្តាប្រទេសផ្សេងៗទៀត គួរតែដំឡើងអត្រាការប្រាក់ដើម្បីការពារសេដ្ឋកិច្ចរបស់ពួកគេ។ ការដំឡើងអត្រាការប្រាក់អាចជួយប្រទេសទាំងនោះការពារលំហូរចេញនៃ មូលធនពីសេដ្ឋកិច្ចរបស់ប្រទេសពួកគេ។ ទោះជាយ៉ាងណា ការ

កើនឡើងនៃអត្រាការប្រាក់លឿនពេក អាចនឹងបង្កើនហានិភ័យនៃការធ្លាក់ចុះសេដ្ឋកិច្ច។

លោក Cochrane ក៏បានបញ្ជាក់ទៀតថា ការផ្ទុះឡើងនៃជំងឺកូវីដ-១៩ នៅទូទាំងតំបន់ កំពុងធ្វើឱ្យតម្រូវការក្នុងស្រុកនៅទ្រឹង និងអតិផរណារក្សានៅកម្រិតមធ្យម។ យោងតាមរបាយការណ៍របស់ធនាគារពិភពលោកដែលទើបនឹងចេញផ្សាយនៅក្នុងខែមិថុនា ឆ្នាំ២០២១ នេះ បានបង្ហាញថា ពីរភាគបីនៃទិន្នផលសេដ្ឋកិច្ចនៅក្នុងប្រទេសអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក នឹងនៅតែស្ថិតនៅក្រោមកម្រិត មុនពេលមានការរាតត្បាតនៃជំងឺកូវីដ-១៩រហូតដល់ឆ្នាំ២០២២។ កត្តាដែលធ្វើឱ្យប៉ះពាល់ដល់សក្តានុពលនៃកំណើនសេដ្ឋកិច្ច ក្នុងប្រទេសទាំងនោះ រួមមាន៖ ការបន្តការរីករាលដាលនៃជំងឺកូវីដ-១៩ និងការដួលរលំនៃវិស័យទេសចរណ៍ជាសកល៕

*ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ គេហទំព័រសារព័ត៌មាន CNBC ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០២១*

## រដ្ឋាភិបាលនៃសហព័ន្ធរុស្ស៊ី គ្រោងបង្កើនការវិនិយោគលើរថយន្តអគ្គីសនី(Electric Vehicle)




Anton Kardashov / Moskva News Agency

រដ្ឋាភិបាលសហព័ន្ធរុស្ស៊ី គ្រោងនឹងចំណាយទុនវិនិយោគ ៧៧៧ ពាន់លានរូប្លិ (១០,៥ពាន់លានដុល្លារ) ដើម្បីអភិវឌ្ឍន៍រថយន្តអគ្គិសនី និងអ៊ីដ្រូសែន(hydrogen vehicle) នៅឆ្នាំ២០៣០។

មន្ត្រីក្រសួងអភិវឌ្ឍន៍សេដ្ឋកិច្ច បានឱ្យដឹងថា ក្នុងរយៈពេល ៩ឆ្នាំខាងមុខ រថយន្តអគ្គិសនីរបស់ប្រទេសរុស្ស៊ី អាចនឹងកើនឡើងពី០,០៥% ដល់ ១៥%។ បើយោងតាមផែនការ គឺ នៅឆ្នាំ ២០៣០ អាចនឹងមានរថយន្តធុនធ្ងន់ចំនួន ១,៥លានគ្រឿងបើកបរនៅលើផ្លូវ និងមានស្ថានីយ៍សាកថ្ម ចំនួន ២០,០០០ស្ថានីយ៍។

ក្រុមហ៊ុនផលិតរថយន្តឈានមុខគេ នៅលើពិភពលោក កំពុងប្រកាស ចេញខ្សែភ្លើងអគ្គិសនីថ្មី។ ភាគច្រើននៃក្រុមហ៊ុនទាំងនោះ គ្រោងនឹងឈប់ផលិតរថយន្តម៉ាស៊ីនចំហេះខាងក្នុងនៅឆ្នាំ២០៣០ នេះបើយោងតាមសម្តីរបស់លោក Ruslan Edelgeriev ទីប្រឹក្សាអាកាស-ធាតុរបស់ប្រធានាធិបតីសហព័ន្ធរុស្ស៊ី វ្លាឌីមៀ ពូទីន ដែលបានលើកឡើងថា ក្នុងរយៈពេល ២០ទៅ៣០ឆ្នាំខាងមុខ មនុស្សម្នាក់ៗនឹងប្តូរទៅប្រើរថយន្តអគ្គិសនីវិញ។

នៅក្នុងឆ្នាំ២០១៩ មានរថយន្តអគ្គិសនីតែ ៣៥៣ គ្រឿង ប៉ុណ្ណោះដែលត្រូវបានលក់នៅលើទីផ្សាររុស្ស៊ី ហើយបើទោះបីជាចំនួននេះកើនឡើងទ្វេដងនៅឆ្នាំ ២០២០ក៏ដោយ ក៏នៅមានត្រឹមតែ ៦៨៧ គ្រឿងដែរ។

នៅឆ្នាំ ២០២០ ប្រជាជនរុស្ស៊ី បានទិញរថយន្តអគ្គិសនី EV(Electric Vehicle) ផលិតដោយក្រុមហ៊ុន Tesla ក្រុមហ៊ុន Porsche ក្រុមហ៊ុនNissan Chevrolet និង ក្រុមហ៊ុនផលិតរថយន្តពិភពលោកផ្សេងទៀត។ ក្រុមហ៊ុន

Ford មានបំណងបើករោងចក្រផលិតរថយន្តអគ្គិសនីដំបូងនៅរុស្ស៊ីនាឆ្នាំ២០២២។ នៅឆ្នាំ២០២០ ក្រុមហ៊ុនផលិតរថយន្តក្នុងស្រុក KamAZ បានបង្ហាញរថយន្ត Kama-1 ដែលជារថយន្តអេឡិចត្រូនិចដំបូងគេរបស់រុស្ស៊ីនៅលើទីផ្សារ។ តំណាងក្រុមហ៊ុនបាននិយាយថា ការអភិវឌ្ឍរថយន្តអគ្គិសនី នៅក្នុងប្រទេសរុស្ស៊ីពិតជាត្រូវការការគាំទ្រពីរដ្ឋាភិបាល។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ The Moscow Times ចុះផ្សាយថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០២១។*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី២៨ ខែមិថុនា ឆ្នាំ២០២១

- អតិរេកពាណិជ្ជកម្មរបស់ប្រទេសម៉ិកស៊ិក ក្នុងខែមេសាឆ្នាំ ២០២១
- អតិរេកពាណិជ្ជកម្មរបស់ប្រទេសអារ៉ាប់ប៊ីសាអូឌីត នៅត្រីមាសទី ៤ នៃឆ្នាំ ២០២០ ។
- កំណើនទំនុកចិត្តលើអាជីវកម្មនៅប្រទេសរុស្ស៊ីក្នុងពីខែមេសា ដល់ខែឧសភា ២០២១។

ថ្ងៃអង្គារ៍ ទី២៩ ខែមិថុនា ឆ្នាំ២០២១

- អតិរេកពាណិជ្ជកម្មរបស់ប្រទេសអាហ្សង់ទីនក្នុងខែមេសាឆ្នាំ ២០២១
- កំណើនអត្រានីកម្មភាព របស់ជប៉ុន នៅក្នុងខែមេសាឆ្នាំ ២០២១
- ការធ្លាក់ចុះអត្រានីកម្មភាព នៅប្រទេសបារាំងនៅត្រីមាសទី៤ នៃឆ្នាំ២០២០។

ថ្ងៃពុធ ទី៣០ ខែមិថុនា ឆ្នាំ២០២១

- កំណើនសកម្មភាពសេដ្ឋកិច្ចរបស់ប្រទេសអាហ្សង់ទីន នាខែមីនាឆ្នាំ ២០២១
- កំណើនផលិតកម្មឧស្សាហកម្មនៅប្រទេសកូរ៉េខាងត្បូង កាលពីខែមេសាឆ្នាំ ២០២១ លើសពីការរំពឹងទុក
- កំណើនឥណទាននៃវិស័យឯកជននៅប្រទេសអូស្ត្រាលី ពីមួយខែទៅមួយខែក្នុងខែមេសាឆ្នាំ ២០២១។

ថ្ងៃព្រហស្បតិ៍ ទី០១ ខែកក្កដា ឆ្នាំ២០២១

- កំណើនសេដ្ឋកិច្ចរុស្ស៊ី កាលពីខែមេសាឆ្នាំ ២០២១
- ការថយចុះ ការវិនិយោគភាគហ៊ុនដោយជនបរទេសនៅក្នុងប្រទេសជប៉ុនគិតត្រឹមថ្ងៃទី ១២ ខែមិថុនាឆ្នាំ ២០២១
- កំណើនអត្រាអតិផរណាប្រចាំឆ្នាំ របស់ឥណ្ឌូនេស៊ី នៅក្នុងខែឧសភាឆ្នាំ ២០២១។

ថ្ងៃសុក្រ ទី០២ ខែមិថុនា ឆ្នាំ២០២១

- អតិរេកពាណិជ្ជកម្មរបស់ប្រទេសប្រេស៊ីល ក្នុងខែឧសភាឆ្នាំ ២០២១
- កំណើនការលក់រាយនៅប្រទេសអាល្លឺម៉ង់ ក្នុងខែមេសាឆ្នាំ ២០២១
- ការធ្លាក់ចុះនៃការនាំចូលទៅប្រទេសកាណាដាពីមួយខែទៅមួយ ឆ្នាំ ២០២១៕